# ចម្រៀង បទ «ឈាមបាតុករ» នាំឱ្យនគរបាលភ្នំពេញហៅមន្ត្រីអង្គការសង្គមស៊ីវិល ៤នាក់ ទៅសាកសួរ។



រូបខាងលើពីឆ្វេងទៅស្តាំ៖ ទី១. លោក អំ សំអាត នាយកទទួលបន្ទុកកិច្ចការទូទៅនៃអង្គការលីកាដូ ទី២. លោក វន់ ពៅ ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) ទី៣. លោក មឿន តុលា នាយកប្រតិបត្តិអង្គការសង់ត្រាល់ (CENTRAL) និងទី៤. លោក ថេង សាវឿន ប្រធានសមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា ជួរខាងក្រោម៖ បាតុកររត់គេចចេញពីការបាញ់បង្ក្រាបរបស់កងកម្លាំងរដ្ឋាភិបាល នៅលើផ្លូវ វេង ស្រេង កាលពីឆ្នាំ២០១៤។

ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ កោះហៅមន្ត្រីអង្គការសង្គមស៊ីវិល ៤នាក់ ឱ្យចូលបំភ្លឺនៅការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យា នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ទាក់ទងនឹងការផ្សព្វផ្សាយបទចម្រៀង ឈាមបាតុករ។ ក្រុមមន្ត្រី

អង្គការសង្គមស៊ីវិល សម្ដែងការហួសចិត្តចំពោះការកោះហៅឱ្យចូលបំភ្លឺរបស់ស្នងការនគរបាលរាជធានីភ្នំពេញនេះ ព្រោះពួកគេអះអាងថាគ្មានផ្នែកណាមួយនៃអត្ថន័យបទចម្រៀង ឈាមបាតុករនេះ អាចនឹងបង្កអសន្តិសុខដល់សង្គមឡើយ។

នាយកទទួលបន្ទុកកិច្ចការទូទៅនៃអង្គការលីកាដូ លោក អំ សំអាត បានចូលទៅឆ្លើយបំភ្លឺនៅស្នងការនគរបាលរាជធានីភ្នំពេញ នៅថ្ងៃទី៩ ខែមករានេះ តាមការកោះហៅ។ លោកបញ្ជាក់ថា ភាគីស្នងការនគរបាលរាជធានីភ្នំពេញ និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ស្នើសុំឱ្យអង្គការលីកាដូ ដកវីដេអូចម្រៀង ឈាមបាតុករ នៅលើបណ្ដាញអ៊ីនធឺណិតរបស់អង្គការលីកាដូចេញវិញ ពីព្រោះពួកគេចោទថា បទចម្រៀងនេះ មានអត្ថន័យញុះញង់ បង្កឱ្យមានអសន្តិសុខ និងសណ្ដាប់សង្គម។ ឆ្លើយតបនឹងការស្នើសុំឱ្យលុបវីដេអូបទចម្រៀងដែលបានផ្សព្វផ្សាយនោះ លោក អំ សំអាត បានឱ្យដឹងថា លោកនឹងពិភាក្សាជាមួយក្រុមការងាររបស់អង្គការលីកាដូ បន្ថែមថា តើត្រូវលុប ឬមិនលុប។ លោកថា បទចម្រៀងដែលនិពន្ធ និងច្រៀងដោយលោក គា សុគន្ធ នេះ មានគោលបំណងបង្ហាញការពិត និងមិនគាំទ្រឱ្យមានអំពើហិង្សានោះឡើយ។

លោក អំ សំអាត៖ *«យើងគ្រាន់តែជម្រាបទៅគាត់អំពីគោលបំណង នៃការបង្ហោះហ្នឹង (វីដេអូចម្រៀង ឈាមបាតុករ) គឺយើងមាន ៣ចំណុច។ ទី១ គឺយើងរំឭកខួប ៩ ឆ្នាំ នៃព្រឹត្តិការណ៍អំពើហិង្សាផ្លូវ វេង ស្រេង និងរោងចក្រយ៉ាក់ជីង។ ចំណុចទី២ គោលបំណងរបស់យើង គឺស្នើសុំឱ្យមានការស៊ើបអង្កេតបន្ត ដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ និងសង្គមជាតិ។ ចំណុចទី៣ គឺរួមគ្នាធ្វើម៉េច ដើម្បីទប់ស្កាត់កុំឱ្យអំពើហិង្សានេះ កើតឡើងបន្តទៀត»។*

លោក អំ សំអាត បានចូលទៅឆ្លើយបំភ្លឺនៅស្នងការនគរបាលរាជធានីភ្នំពេញនេះ នៅបន្ទាប់ពីស្នងការនគរបាលរាជធានីភ្នំពេញ កាលពីថ្ងៃទី៧ មករា បានចេញ

លិខិតអញ្ជើញមន្ត្រីអង្គការសង្គមស៊ីវិល ៤នាក់ ឱ្យចូលខ្លួនឆ្លើយបំភ្លឺ ទាក់ទងនឹងការផ្សព្វផ្សាយបទចម្រៀង ឈាមបាតុករ នៅការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យា នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។ លិខិតអញ្ជើញ ៤ដាច់ដោយឡែកពីគ្នានេះ បានកោះហៅនាយកទទួលបន្ទុកកិច្ចការទូទៅនៃអង្គការលីកាដូ លោក អំ សំអាត ឱ្យចូលខ្លួនឆ្លើយបំភ្លឺនៅថ្ងៃទី៩ ខែមករា។ ដោយឡែក ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) លោក វន់ ពៅ និងនាយកប្រតិបត្តិអង្គការសង់ត្រាល់ (CENTRAL) លោក មឿន តុលា ត្រូវបានស្នងការនគរបាលរាជធានីភ្នំពេញ កោះហៅឱ្យចូលឆ្លើយបំភ្លឺនៅថ្ងៃទី១០ ខែមករា។ ចំណែកឯប្រធានសមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា លោក ថេង សាវឿន ឱ្យចូលបំភ្លឺនៅថ្ងៃទី១១ មករា។

ដោយឡែកនៅខាងក្រៅរបងស្នងការនគរបាលរាជធានីភ្នំពេញ គឺមានមន្ត្រីអង្គការសហប្រជាជាតិ អង្គការសង្គមស៊ីវិល និងក្រុមអ្នកសារព័ត៌មាន ជិត២០នាក់ តាមឃ្លាំមើល។

ការកោះហៅឱ្យមន្ត្រីអង្គការសង្គមស៊ីវិល ចូលខ្លួនបំភ្លឺនេះ គឺធ្វើឡើងបន្ទាប់ពី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អ្នកស្រី ភឿង សកុណា កាលពីថ្ងៃទី៦ ខែមករា បានចេញលិខិតស្នើសុំឲ្យអគ្គស្នងការនគរបាលជាតិ លោក នេត សាវឿន ចាត់វិធានការតាមផ្លូវច្បាប់ ចំពោះការផ្សព្វផ្សាយបទចម្រៀងដែលមានចំណងជើងថា ឈាមបាតុករ។ អ្នកស្រីចោទប្រកាន់ថា បទចម្រៀងនេះ មានខ្លឹមសារញុះញង់ អាចបង្កជាអសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម។ ការស្នើសុំនេះ ធ្វើឡើងបន្ទាប់ពីក្រុមអង្គការសង្គមស៊ីវិលបានផ្សព្វផ្សាយវីដេអូបទចម្រៀងឈាមបាតុករនៅលើបណ្តាញសង្គមហ្វេសប៊ុក (Facebook) ក្នុងឱកាសខួប ៩ឆ្នាំ នៃការបាញ់បង្ក្រាបបង្ហូរឈាមពីសំណាក់រដ្ឋាភិបាលទៅលើក្រុមបាតុករនៅលើផ្លូវ វេង ស្រេង។ បទ

ចម្រៀងនេះត្រូវបាននិពន្ធ និងច្រៀងដោយលោក គា សុគន្ធ ដែលធ្លាប់បានជាប់ពន្ធនាគារកន្លងរួចមកហើយ កាលពីចុងឆ្នាំ២០២០ ដោយសារតែបានផ្សព្វផ្សាយបទចម្រៀងបែបរ៉ែប (RAP) ដែលមានអត្ថន័យបង្ហាញអំពីបញ្ហាសង្គមក្នុងប្រទេសកម្ពុជា។

ជុំវិញរឿងនេះ ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) លោក វន់ ពៅ ប្រាប់វិទ្យុអាស៊ីសេរីថា លោកហួសចិត្តនៅពេលដែលស្នងការនគរបាលរាជធានីភ្នំពេញ កោះហៅលោកឱ្យចូលឆ្លើយបំភ្លឺ ទាក់ទងនឹងការផ្សព្វផ្សាយបទចម្រៀង ឈាមបាតុករ នេះ។ លោកបន្ថែមថា អាជ្ញាធរមិនគួរកោះហៅលោកឱ្យចូលខ្លួនឆ្លើយបំភ្លឺនេះឡើយ ព្រោះការផ្សព្វផ្សាយបទចម្រៀង ឈាមបាតុករ គ្រាន់តែចង់បង្ហាញការពិតពីអំពើហិង្សា ដែលកើតមានឡើងកាលពី៩ឆ្នាំមុន និងជំរុញឱ្យភាគីពាក់ព័ន្ធរកយុត្តិធម៌ដល់ជនរងគ្រោះតែប៉ុណ្ណោះ។

លោក វន់ ពៅ៖ *«ខ្ញុំមានអារម្មណ៍ថាហួសចិត្ត ហើយមានអារម្មណ៍ថាដូច សង្វេគនៅក្នុងជីវិត ក្នុងនាមជាពលរដ្ឋខ្មែរដែលធ្វើការដើម្បីការពារប្រយោជន៍កម្មករសោះបែរជា រងនូវព្យុះភ្លៀងអត់មានស្រាកស្រាន្ត ទាំងព្យុះភ្លៀងទៅលើខ្សែជីវិត ទាំងទៅលើរូបរាងកាយ ទាំងទៅលើផ្លូវចិត្ត នៃការបំពេញបេសកកម្មការងារ»*។

ក្នុងនាមជាជនរងគ្រោះម្នាក់ដែលទទួលរងអំពើហិង្សា ក្នុងព្រឹត្តិការណ៍បង្ក្រាបបាតុកម្មដោយហិង្សានៅផ្លូវ វេង ស្រេង កាលពីខែមករា ឆ្នាំ២០១៤ លោក វន់ ពៅ និយាយថា អាជ្ញាធរមានសមត្ថកិច្ច ត្រូវមានវិធានការផ្លូវច្បាប់ទៅលើជនដៃដល់ដែលបានប្រើអំពើហិង្សាលើក្រុមបាតុករឱ្យបានឆាប់ ជាជាងព្យាយាមគំរាមកំហែងការផ្សព្វផ្សាយបទចម្រៀង ដែលទាមទារឱ្យមានយុត្តិធម៌ដល់ជនរងគ្រោះនេះ។

វីដេអូបទចម្រៀង "ឈាមបាតុករ" បានបង្ហាញរូបភាពសមត្ថកិច្ចបាញ់ និងវាយបង្ក្រាបដើម្បីបំបែកហ្វូងបាតុករ ដែលតវ៉ាទាមទារដំឡើងប្រាក់ខែ នៅលើផ្លូវ វេង

ស្រេង កាលពីឆ្នាំ២០១៤។ វីដេអូបទចម្រៀងបែបរ៉ែបនេះមានអត្ថន័យរំលឹកដល់វីរភាពរបស់សហជីព និងអ្នកតស៊ូ ដើម្បីសិទ្ធិការងារ និងទាមទារដំឡើងប្រាក់ឈ្នួល ដែលបានយកសាច់ស្រស់ឈាមស្រស់ទៅតទល់ ដោយមិនខ្លាចជាមួយដំបងដែក គ្រាប់កាំភ្លើងរបស់កម្លាំងសមត្ថកិច្ច ដើម្បីទទួលបានប្រាក់ខែសមរម្យ។

ជុំវិញរឿងនេះ នាយិកាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា អ្នកស្រី ចក់ សុភាព លើកឡើងថា ការកោះហៅក្រុមមន្ត្រីអង្គការសង្គមស៊ីវិលឱ្យចូលខ្លួនបំភ្លឺនេះ គឺជាការគំរាមកំហែងលើសិទ្ធិសេរីភាពបញ្ចេញមតិបន្ថែមទៀត ខណៈសេរីភាពបញ្ចេញមតិនៅប្រទេសកម្ពុជាកំពុងតែដើរថយក្រោយ ពីមួយឆ្នាំទៅមួយឆ្នាំ។ អ្នកស្រីមានប្រសាសន៍ថា បទចម្រៀង ឈាមបាតុករ ដែលក្រុមអង្គការសង្គមស៊ីវិលផ្សព្វផ្សាយ គ្រាន់តែជាការបង្ហាញការពិតពីបញ្ហាសង្គម និងទាមទារឱ្យមានយុត្តិធម៌ទៅដល់ជនរងគ្រោះប៉ុណ្ណោះ។

អ្នកស្រី ចក់ សុភាព៖ *«នៅពេលដែលមានការរិះគន់ហ្នឹង គេមិនលើកទឹកចិត្តឱ្យថ្នាក់ដឹកនាំ ឬក៏បុគ្គលសាធារណៈហ្នឹងប្រើប្រាស់មធ្យោបាយរដ្ឋ ឬក៏ធនធានទាំងឡាយហ្នឹង ដើម្បីទៅដាក់គំនាប ឬក៏ប្ដឹងផ្ដល់ទៅដល់ពលរដ្ឋអញ្ចឹងទេ គឺគេឱ្យមានការអនុគ្រោះឱ្យបានច្រើន ហើយត្រូវទទួលយកមតិទាំងអស់ហ្នឹង មតិរិះគន់ហ្នឹងនិយាយទៅគេមិនលើកទឹកចិត្តយើងឱ្យប្រើនីតិវិធីច្បាប់ទេ ព្រោះនៅពេលដែលយើងក្លាយជាមេដឹកនាំ យើងជាបុគ្គលសាធារណៈ គឺយើងក្លាយជាកម្មវត្ថុនៃការរិះគន់»។*

ទាក់ទងនឹងបញ្ហានេះ ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) លោក វន់ ពៅ និង នាយកប្រតិបត្តិអង្គការសង់ត្រាល់ (CENTRAL) លោក មឿន តុលា ប្រាប់វិទ្យុអាស៊ីសេរីថា ពួកគាត់នឹងចូលខ្លួនឆ្លើយបំភ្លឺតាមការកោះហៅ នៅថ្ងៃទី១០ ខែមករា។ ដោយឡែក ប្រធានសមាគមស

ម្ព័ន្ធសហគមន៍កសិករកម្ពុជា លោក ថេង សាវឿន ក៏ឱ្យដឹងដែរថា គាត់នឹងចូលឆ្លើយបំភ្លឺនៅថ្ងៃទី១៧ មករាវិញ ហើយលោកបានដាក់ពាក្យសុំពន្យារពេលចូលខ្លួនឆ្លើយបំភ្លឺរួចហើយ។

អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ តែងលើកឡើងថា រដ្ឋាភិបាលតែងតែធ្វើទុក្ខបុកម្នេញទៅលើអ្នកដែលមានភាពក្លាហាន បញ្ចេញមតិ បង្ហាញការពិតពីបញ្ហានៅក្នុងសង្គម។ ពួកគេលើកឡើងថា រដ្ឋាភិបាលគួរតែលើកកម្ពស់សេរីភាពបញ្ចេញមតិ និងដោះស្រាយបញ្ហានានា ដែលប្រជាពលរដ្ឋបានលើកឡើង ជាជាងគំរាមកំហែងទៅលើអ្នកដែលក្លាហានបញ្ចេញមតិ ហើយមិនដោះស្រាយបញ្ហាអយុត្តិធម៌សង្គមបែបនេះទៅវិញ៕